ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ......១១៣/៧១.......គ.ជ.ប.ជ

# របាយការណ៍
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រឆាំងការជួញដូរមនុស្ស ឆមាសទី១ របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

តាមប្រព័ន្ធអនឡាញ នាថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២១

កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រឆាំងការជួញដូរមនុស្ស ឆមាសទី១របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ត្រូវបានរៀបចំតាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ ២០២១ ។ កិច្ចប្រជុំនេះ មានការចូលរួមពីឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី និងឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ជាអនុប្រធាន និងជាប្រធានដឹកនាំក្រុមការងារអន្តរក្រសួងស្ថាប័ន ទាំង ០៦ នៃ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខា ធិការ អគ្គនាយក អគ្គនាយករង តំណាងក្រសួង ស្ថាប័ន និងអង្គភាពជាសមាជិក សរុប ៧៣នាក់ ។

**សម្តេចក្រឡាហោម** ប្រធានគណៈកម្មាធិការជាតិ បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានដ៏មានសារសំខាន់ ។ បន្ទាប់មក លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើរបាយការណ៍ សង្ខេប ស្តីពីលទ្ធផលការងាររបស់គណៈកម្មាធិការជាតិ ដែលគ្រប់ក្រសួងស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានខិតខំប្រឹងប្រែងបំពេញភារកិច្ច ឲ្យសម្រេចបានលទ្ធផលគួរជាទីមោទនៈ ក្នុងដំណាក់កាលដ៏លំបាកដែលបាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅ បណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ ១៩ និងមេរោគបម្លែងថ្មី ។ សមា ជិកគណៈកម្មាធិការជាតិ គ្រប់ថ្នាក់ បានខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីអនុវត្តនូវយុទ្ធសាស្ត្រទាំងបួនគឺ (១) ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ (២) ការងារបង្ការទប់ស្កាត់ (៣)ការងារ អនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ (៤) កិច្ចការពារជនរងគ្រោះ ដោយបញ្ចៀសឲ្យបានជាអតិបរមា នូវហានិភ័យពាក់ព័ន្ធនឹងការឆ្លង និងចម្លង កូវីដ ១៩ ។ ជាក់ស្តែង ការបង្ការទប់ស្កាត់តាមវិធីអប់រំផ្សព្វផ្សាយ ដោយផ្ទាល់ និងដោយប្រយោលព្រមជាមួយវិធានការជំនាញជាច្រើនទៀត បានដល់មនុស្ស ប្រមាណជាងពីរលាននាក់ ដើម្បីបានយល់ដឹងអំពីកលល្បិចថ្មីៗនៃជនជួញដូរមនុស្ស និងវិធានការផ្សេងៗរបស់រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នជំនាញ ។

ចំណែកឯការងារអនុវត្តច្បាប់ កម្លាំងសមត្ថកិច្ចនគរបាលយុត្តិធម៌ បានបង្ក្រាបករណីជួញដូរមនុស្ស ច្រើនជាងឆ្នាំមុនបើគិតក្នុងរយៈពេលដូចគ្នា គឺ១៩៨ករណី ដែលក្នុងឆមាសទី១ឆ្នាំ២០២០ បង្ក្រាបបាន ៦៣ករណី គឺកើន ១៣៥ករណី (ស្មើនឹង ២១៤.២៨%) ក្នុងនោះ ពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស បង្ក្រាបបាន ១៣៩ករណី/១៦ករណី (កើនឡើង ១២៣ករណី ) និងបទល្មើសអាជីវកម្មផ្លូវភេទ បង្ក្រាបបាន៥៩ករណី/៤៧ករណី( កើន១២ករណី ) ។

គិតត្រឹមឆ្នាំ២០២០ ទីភ្នាក់ងារជ្រើសរើសឯកជនដែលទទួលបានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស មានចំនួន១២៦នាក់ ។ កន្លងមក ក្រសួង ធ្លាប់បាន

ដាក់កំហិត និងដកអាជ្ញាប័ណ្ណពីក្រុមហ៊ុន ដូចជានៅក្នុងឆ្នាំ២០២០នេះ ក្រសួងបានដាក់កំហិតឲ្យកែលម្អក្រុមហ៊ុនចំនួន២ និងបានដកអាជ្ញាប័ណ្ណពីក្រុមហ៊ុនចំនួន១ ផងដែរ។

ដោយឡែក ការងារផ្តន្ទាទោសក៏បានបង្កើនល្បឿន ក្នុងការបើសវនាការតាមគោលការណ៍កំណែទម្រង់ការងាររបស់ក្រសួងយុត្តិធម៌ ។ ជាក់ស្តែងចំណាត់ការរបស់ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត លើករណីពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស សរុបបានចំនួន ៤០៥សំណុំរឿង ជនរងគ្រោះចំនួន ៣៨៤នាក់(ស្រី ១៦២នាក់) ក្នុងនោះមានអនីតិជន ១៤២នាក់(ស្រី៧៥នាក់) ជនត្រូវចោទមានចំនួន ៤៣៨នាក់(ស្រី ១៦០នាក់) ក្នុងនោះមានអនីតិជន ១៥នាក់(ស្រី ០២នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ៣៤៤សំណុំរឿង តម្កល់ទុកឥតចាត់ការ ១០សំណុំរឿង បញ្ជូនរឿងទៅជម្រះផ្ទាល់ ០៧សំណុំរឿង នីតិវិធីបង្ហាញខ្លួនភ្លាម ០២សំណុំរឿង និងកំពុងចាត់ការចំនួន ៤២សំណុំរឿង។ ឯចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៣៣២សំណុំរឿង ជនរងគ្រោះចំនួន ៣៩៦នាក់ (ស្រី ១៨១នាក់) ក្នុងនោះមានអនីតិជន ១៣៨នាក់(ស្រី ១២៣នាក់) ជនត្រូវចោទមានចំនួន ៤៥៤នាក់ (ស្រី ៩២នាក់) ក្នុងនោះមានអនីតិជន ៧៥នាក់ (ស្រី ១០នាក់) ក្នុងនោះបានចំណាត់ការ(បញ្ជូនទៅជម្រះចំនួន ១១៧សំណុំរឿង លើកលែងចោទ ០៥សំណុំរឿង និងកំពុងចាត់ការចំនួន ២១០សំណុំរឿង)។ ចំពោះដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ២០៤ សំណុំរឿង ជនរងគ្រោះចំនួន ១៨៧នាក់(ស្រី ៨១នាក់) ក្នុងនោះមានអនីតិជន ៨៣នាក់(ស្រី ៧៥នាក់) ជនជាប់ចោទសរុប ១៩៩នាក់(ស្រី ៨១នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរទោសសាកល្បង ០២សំណុំរឿង ពិន័យជាប្រាក់ ០១សំណុំរឿង រួចផុតពីបទចោទ ០៤សំណុំរឿង ចាត់ការរួច ៦៥សំណុំរឿង ផ្តន្ទាទោសដាក់ពន្ធនាគារ ៣៧សំណុំរឿង និងកំពុងចាត់ការ ១៣៩សំណុំរឿង)។

ចំណែកឯការងារការពារជនរងគ្រោះ ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសម្របសម្រួលឲ្យពលរដ្ឋខ្មែរ ដែលមានបញ្ហាប្រឈមនៅក្រៅប្រទេស បានវិលត្រឡប់មកកម្ពុជាវិញ សរុបទាំងអស់២.៣១៧នាក់ (ស្រី ៩៧២នាក់) ក្នុងនោះ មួយចំនួន សង្ស័យថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងមានពលករខុសច្បាប់ដែលត្រូវវិលត្រឡប់មកពីប្រទេសថៃមានហូតដល់ ១.៦០៨នាក់ ស្រី ៤៨០នាក់ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលពលរដ្ឋខ្មែរដែលបានធ្វើមាតុភូមិនិវត្តន៍ពីបរទេស និងទទួលពីអាជ្ញាធរប្រទេសនានា សរុបចំនួន ៤០.៨២២នាក់(ស្ត្រី ១៦.១៣៣នាក់ កុមារា ២.៣៩៥នាក់ កុមារី ២.១៧៥នាក់ ក្នុងចំណោមនោះ មាន អ្នកដែលសង្ស័យថារងគ្រោះ ២២៤នាក់ (ស្ត្រី ១៧៤នាក់ កុមារា ០៤នាក់ កុមារី ៣០នាក់) មកពីប្រទេស ចិន ១៧៧នាក់ ពីវៀតណាម(ឆ្លងទៅចិន) ១៤នាក់ ពីថៃ១៤នាក់ ពីឥណ្ឌូនេស៊ី ០១នាក់ ពីប្រទេសម៉ាឡេស៊ី ១៤នាក់ និងពីសឹង្ហបូរី ០៤នាក់ ដែលក្រោយការសម្ភាសន៍ សង្ស័យថារងគ្រោះដោយករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់ ជួញដូរកម្លាំងពលកម្ម ១១នាក់ អាពាហ៍ពិពាហ៍ផ្ទុយពិធនុះ/បង្ខំ ១៦២នាក់ និង ករណីងាយរងគ្រោះ ៣២នាក់ ។

ក្នុងចំណោមពលករដែលត្រូវអាជ្ញាធរប្រទេសថៃបញ្ជូនមក មានសរុបចំនួន ៤០.៥៩៨នាក់ (ស្ត្រី១៥. ៩៥៩នាក់ កុមារា ២.៣៩១នាក់ កុមារី ២.១៤៥នាក់) មណ្ឌលសំចត ទទួលពលករនៅប៉ោយប៉ែត បានធ្វើការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណ រកឃើញមុខសញ្ញាសង្ស័យថាជាជនរងគ្រោះ ដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់ និងជាជនងាយរងគ្រោះ ៤៣នាក់ និងបានបញ្ជូន ទៅទទួលសេវាបន្តនៅអង្គការដៃគូដូចជា អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការភឿន អង្គការសាម៉ារីតាន់ភឺស និងអង្គការរតនៈអ៊ិនធើណេសិនណល ជាដើម ។

ទន្ទឹមនឹងនោះ នាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួល និងសម្ភាសជនរងគ្រោះ និងជនទេសន្តប្រវេសន៍ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១១១នាក់(ស្រី៩៧នាក់) ក្នុងនោះ មកពីប្រទេសចិនចំនួន៩៩នាក់(ស្រី៩៦នាក់) ឥណ្ឌូនេស៊ី០១នាក់ និងប្រទេសម៉ាឡេស៊ីចំនួន

១០នាក់(ស្រី០១នាក់)និងសង្ហបុរី០១នាក់។ តាមលទ្ធផលនៃការបំភ្លឺរបស់ជនរងគ្រោះ បានឲ្យដឹងថាអ្នកទៅតាមរយៈមេខ្យល់ស្គាល់អត្តសញ្ញាណ០៤នាក់ ទៅតាមរយៈមេខ្យល់មិនស្គាល់អត្តសញ្ញាណចំនួន ១០៦ និងទៅតាមក្រុមហ៊ុន ០១នាក់ បច្ចុប្បន្នជនរងគ្រោះប្រគល់ឲ្យមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្តារនីតិសម្បទា ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តចុះធ្វើអធិការកិច្ចការងារដោយមិនជូនដំណឹង នៅគ្រប់មុខរបរដែលជាវិស័យអាទិភាព និងមានហានិភ័យខ្ពស់ ដូចជាវិស័យកាត់ដេរ សិប្បកម្មផលិតឥដ្ឋ សេវា កំសាន្ត សំណង់ និងចម្ការកសិកម្ម ដោយផ្តោតសំខាន់លើការពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងទប់ស្កាត់ ការងារដោយបង្ខំ ជាពិសេស ទាសភាពបំណុល។ ជាក់ស្តែង ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ ក្រសួងបានជួយកុមារងាយរងគ្រោះបានចំនួន ១២០០ករណី ដើម្បីឱ្យពួកគេទទួលបានការអប់រំ បណ្តុះបណ្តាលជំនាញ និងបង្កើតមុខរបរបំពេញបន្ថែមសម្រាប់គ្រួសារកុមារដែលក្រីក្រ។

ដើម្បីពង្រឹងលក្ខខណ្ឌការងារ និងការពារសិទ្ធិកម្មករពីការរំលោភបំពាន ទាសភាពបំណុល និង ពលកម្មកុមារឱ្យកាន់តែប្រសើរឡើង ក្រុមអធិការកិច្ចអន្តរក្រសួង ត្រូវបានបង្កើតឡើងនៅក្នុងវិស័យឧស្សាហកម្ម ទេសចរណ៍ តាមរយៈប្រកាសអន្តរក្រសួងលេខ ០៦៥/២១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១, នៅក្នុងវិស័យ កសិកម្ម តាមរយៈប្រកាសអន្តរក្រសួងលេខ ០៦៤/២១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ និងនៅក្នុងវិស័យ កម្មន្តសាល តាមរយៈប្រកាសអន្តរក្រសួងលេខ០៧៣/២០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។

ចំពោះការផ្តល់សេវា និងស្តារនីតិសម្បទា ជនរងគ្រោះ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតសម្បទា** (ស.អ.យ) ក្រុមការងារការពារជនរងគ្រោះ និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន **២៣៩**នាក់ (ស្ត្រី **១៥៣**នាក់ កុមារា **១៥**នាក់ កុមារី **៦៧**នាក់) ជាករណី(*ងាយរងគ្រោះ ២៥នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០៧នាក់)* ដែលក្នុងនោះមាន ការផ្តល់សេវាពី មន្ទីរស.អ.យ រាជធានី ខេត្ត ៨០នាក់ និងអង្គការដៃគូ **១៥៩**នាក់ ។

ទន្ទឹមនឹងនោះដែរ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**(ស.អ.យ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន ៦៨នាក់ (ស្ត្រី៦៤នាក់) ក្នុងនោះជាករណី(*អាពាហ៍ពិពាហ៍ដោយផ្ទុយពីឆន្ទៈ/បង្ខំ៦២នាក់ ជួញដូរកម្លាំងពលកម្ម០៤នាក់ រំលោភបំពានផ្លូវភេទ០២នាក់*) ដោយមានកិច្ចសហការពីអង្គការដៃគូក្នុងការបញ្ជូន។

ចំពោះការងារបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងកិច្ចប្រជុំ ថ្នាក់ជាតិ និងអន្តរជាតិ ត្រូវបានធ្វើឡើង តាមប្រព័ន្ធអនឡាញ ដើម្បីកាត់បន្ថយការជួបជុំ ដែលប្រឈមនឹងហានិភ័យនៃការឆ្លង និងចម្លងកូវីដ ១៩ ។

ទិសដៅ សម្រាប់ឆមាសទី២ ឆ្នាំ២០២១ គណៈកម្មាធិការជាតិ បានកំណត់យក តាមយុទ្ធសាស្ត្រ ដែលក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងបន្តជម្រុញអនុវត្ត គឺ (១) ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ មាន ០៩សកម្មភាព (២) ការងារបង្ការទប់ស្កាត់ មាន ១៦សកម្មភាព (៣) ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ មាន ០៥សកម្មភាព (៤) ការងារការពារជនជនរងគ្រោះ មាន ១២សកម្មភាព និងបន្ថែម ការងារពង្រឹងសមត្ថភាព និងការតាមដាន ត្រួតពិនិត្យ មាន ០៧សកម្មភាព ។

***លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍*** បានធ្វើរបាយការណ៍បន្ថែមផងដែរ អំពីលទ្ធផលនៃការវាយតម្លៃរបស់សហរដ្ឋអាមេរិក លើកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីឃ្លាំមើល ។ ក្នុងនោះ អនុសាសន៍ជាផែនការសម្រាប់ការអនុវត្តឆ្នាំ២០២២ ដែលមាន ១៦ចំណុច (ឆ្នាំ២០២១ មាន ១៧ចំណុច) ដែលដកចេញនូវចំណុច ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីស៊ើបអង្កេតសម្ងាត់ ក្រោយ

ពីមានការបកស្រាយពន្យល់យ៉ាងល្អិតល្អន់ ពីឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ជូនអ្នកជំនាញពីសហរដ្ឋអាមេរិក និងបានយល់ស្របគ្នានីតិវិធីស៊ើបអង្កេតតាមច្បាប់កម្ពុជា រួចមក ។

**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានសម្តែងនូវអំណរសាទរ និងការកោតសរសើរ ចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃគ្រប់ក្រសួងស្ថាប័ន ក្នុងគណៈកម្មាធិការជាតិ គ្រប់ថ្នាក់ រួមទាំងកងកម្លាំងសមត្ថកិច្ចគ្រប់ផ្នែក ស្ថាប័នអយ្យការ ស្ថានបេសកកម្មការទូត នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបាននាំគ្នាជម្រុញអនុវត្តសកម្មភាពទោះបីជាបាន និងកំពុងប្រឈមដោះស្រាយបញ្ហាផ្សេងៗ រួមទាំងវិបត្តិកូវីដ ១៩ ក៏ដោយ និងបើកការពិភាក្សា ផ្តល់យោបល់បន្ថែម លើរបាយការណ៍ឆមាសទី និងទិសដៅឆមាសទី២ ឆ្នាំ២០២១ ។ ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានឯកភាពលើរបាយការណ៍ និងទិសដៅ ព្រមទាំងបានបញ្ជាក់បន្ថែមលើការកែសម្រួលយន្តការ និងនីតិវិធីនៃការងារផ្តន្ទាទោស ដែលពន្លឿនដល់សវនាការ និងការផ្តល់របាយការណ៍កាន់តែជាក់លាក់ និងទាន់ពេលវេលា ។ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏បានសម្តែងនូវការឯកភាពខ្ពស់ លើការវាយតម្លៃសភាពការណ៍ លទ្ធផលការងារ និងទិសដៅដែលបានលើកឡើងក្នុងរបាយការណ៍ និងបានបង្ហាញពីការប្តេជ្ញាចិត្តថានឹងជម្រុញអនុវត្តឲ្យបានសម្រេច រួមទាំងអនុសាសន៍ប្រាំចំណុច ដែលជាអនុសាសន៍របស់សហរដ្ឋអាមេរិក ។ លោកជំទាវ កិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក៏បានបញ្ជាក់ពីការឯកភាព និងបានជម្រាបជូនអំពីកិច្ចសហការជាមួយស្ថានទូតអាមេរិក ដែលធ្វើឡើងតាមរយៈជំនួបរវាងក្រុមការងារអន្តរក្រសួងជំនាញ ជាមួយឯកឧត្តម ឯកអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាព សហរដ្ឋអាមេរិក និងគណៈប្រតិភូ ដើម្បីពិភាក្សាការងារ ជាបន្តបន្ទាប់ និងត្រូវបន្តជួបទៀត តែត្រូវបានផ្អាក ដោយការផ្ទុះជាថ្មី នៃកូវីដ ១៩ ។

ជាចុងក្រោយ **សម្តេចក្រឡាហោម** ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ប្រធានអង្គប្រជុំ បានផ្តាំផ្ញើឲ្យក្រសួងស្ថាប័ន បន្តជម្រុញអនុវត្តសកម្មភាពទាំងឡាយ តាមការគ្រោងទុក និងត្រូវខិតខំពង្រឹងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ទាំងស្ថានទូតអាមេរិក និងគ្រប់ស្ថានទូតប្រទេសជាមិត្ត អង្គការជាតិ និងអន្តរជាតិ អង្គការសហប្រជាជាតិ ដែលបាន និងកំពុងរួមគ្នាជួយគាំទ្រ និងសហការរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បី ធ្វើឲ្យសម្រេចលទ្ធផលតាមការគ្រោងទុក ដោយពុះពារគ្រប់ឧបសគ្គ និងភាពប្រឈមទាំងឡាយ និងរួមគ្នារៀបចំទិន្នន័យ ដើម្បីចងក្រងជាប្រព័ន្ធ ដែលស៊ីសង្វាក់គ្នា សម្រាប់ប្រើប្រាស់ជារបាយការណ៍ជាតិ និងសម្រាប់ការចែកផ្សាយទូលំទូលាយ ។

កិច្ចប្រជុំបានបញ្ចប់ទៅក្រោមបរិយាកាសរីករាយ និងប្រកបដោយលទ្ធផលជាផ្លែផ្កា ។

ថ្ងៃ...៥ ៨កើត.....ខែ...ស្រាពណ៍......ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.....១៦.....ខែ...សីហា.....ឆ្នាំ២០២១

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**